ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:..................................គ.ម.ក

# លទ្ធផលកិច្ចប្រជុំ
# គណៈកម្មការមូលបត្រកម្ពុជាលើកទី ៣២

នៅរសៀលថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា(**គ.ម.ក**) បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជាលើកទី ៣២។ ក្នុងកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជាលើកទី ៣២ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាលើរបៀបវារៈស្តីពី÷

**១.** ពិនិត្យ និងពិភាក្សាលើសំណើសុំកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ ដើម្បីកែប្រែការជួញដូរពី ៦ វគ្គទៅការជួញដូរជាប់ជានិរន្តរ ឬជាប់ឥតដាច់ (Continuous Trading) ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ ១១:០០ ព្រឹក។

**២.** ពិនិត្យ និងពិភាក្សាលើសំណើសុំកែប្រែវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ ក្នុងការអនុវត្តការជួញដូរមុនការទូទាត់ (Trading Before Settlement)។

**៣.** ពិនិត្យ និងពិភាក្សាលើសំណើសុំកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដើម្បីកែប្រែដែនកំណត់ថ្លៃចុះបញ្ជីលក់លើកដំបូងពី[៩០%-១៥០%] មក[៩០%-១២០%] និងកែប្រែកែប្រែលក្ខខ័ណ្ឌចុះបញ្ជីភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង១% ពី១៥% មក ១០%។

**៤.** ផ្សេងៗ។

បន្ទាប់ពីអង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងល្អិតល្អន់ទៅលើខ្លឹមសារបច្ចេកទេសលើបទបង្ហាញរបស់មន្ត្រីជំនាញ **គ.ម.ក.** និងដោយផ្អែកលើស្ថានភាពចាំបាច់នៃទីផ្សារមូលបត្រកម្ពុជានាពេលបច្ចុប្បន្ន និងដើម្បីជំរុញការជួញដូរមូលបត្រ អង្គប្រជុំបានអនុម័តជាគោលការណ៍÷ (១).ធ្វើការកែប្រែការជួញដូរពី ៦ វគ្គ ទៅជាការជួញដូរជាប់ជានិរន្តរ ឬជាប់ឥតដាច់ (Continuous Trading) ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ ១១:០០ ព្រឹក និងបានសម្រេចឱ្យមន្ត្រីជំនាញពិនិត្យរៀបចំកែសម្រួលលើវិធាននេះឱ្យបានរលូនមុនដាក់ជូន **គ.ម.ក.** ពិនិត្យ និងសម្រេចក្នុងកិច្ចប្រជុំលើកក្រោយ។ (២).អនុញ្ញាតឱ្យមានការជួញដូរមូលបត្រមុនការទូទាត់(Trading Before Settlement) វិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ ដោយបានអនុម័តធ្វើការកែប្រែវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ ក្នុងគោលបំណងជំរុញទីផ្សារឱ្យមានសន្ទនីយភាពខ្ពស់ជាងមុន ក៏ដូចជាកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការប្រែប្រួលថ្លៃមូលបត្រក្នុងថ្ងៃឬឆ្លងថ្ងៃ។ការជួញដូរមូលបត្រមុនការទូទាត់នេះអនុញ្ញាតឱ្យវិនិយោគិនអាចធ្វើការជួញដូរបានលើទឹកប្រាក់ និងមូលបត្រដែលបានផ្ទៀងផ្ទាត់នៅថ្ងៃ T+0 ដោយមិនចាំបាច់រង់ចាំរហូតដល់ថ្ងៃទូទាត់នៅ T+2 ។ (៣).អង្គប្រជុំបានសម្រេចរក្សាដែនកំណត់ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រចុះបញ្ជីលក់លើកដំបូងនៅដដែល និងបានណែនាំឱ្យមន្ត្រីជំនាញធ្វើការសិក្សាបន្ថែមលើកត្តាផ្សេងៗ ដែលមានការពាក់ព័ន្ធនឹងឥទ្ធិពលថ្លៃ IPO ក៏ដូចជាកត្តាផ្សេងៗពាក់ព័ន្ធនឹងការកំណត់ថ្លៃ IPO រួមទាំងពិនិត្យយន្តការធ្វើ Book Building ផងដែរ។ អង្គប្រជុំក៏បានសម្រេចរក្សាលក្ខខ័ណ្ឌចុះបញ្ជីភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% នៅ ១៥% ដដែល និងបានណែនាំមន្ត្រីជំនាញ បន្តពិនិត្យមើលការវិវត្តជាក់ស្តែងជាបន្តទៀតថាតើលក្ខខ័ណ្ឌនេះពិតជាកត្តារាំងស្ទះដល់កិច្ចដំណើរការចុះបញ្ជីឬទេ។

នៅក្នុងរបៀបវារៈផ្សេងៗ អង្គប្រជុំ (១) ពិនិត្យលើរបាយការណ៍នាយកដ្ឋានជំនាញនៃ **គ.ម.ក.** ពីវឌ្ឍនភាពការងាររបស់ក្រុមហ៊ុនផ្សេងៗទៀត ដែលកំពុងរៀបចំបោះផ្សាយលក់មូលបត្រ (IPO)។ អង្គប្រជុំបានណែនាំដល់មន្ត្រីជំនាញនៃ **គ.ម.ក** បន្តដោះស្រាយការងារដែលនៅសេសសល់ ដើម្បីជំរុញការងារបោះផ្សាយលក់មូលបត្រឱ្យបានឆាប់។ (២) អង្គប្រជុំបានពិនិត្យលើលទ្ធផលនៃការជួញដូររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) និងក្រុមហ៊ុន Grant Twin International (GTI) ក្នុងរយៈពេលកន្លងមក និងបានណែនាំដល់មន្ត្រីជំនាញនៃ **គ.ម.ក.** បន្តតាមដានការជួញដូរមូលបត្រនៅលើទីផ្សារជាបន្តទៀត និងជំរុញការផ្សព្វផ្សាយព័ត៌មានសាធារណៈរបស់ក្រុមហ៊ុនចុះបញ្ជីដល់សាធារណជនឱ្យបានទូលំទូលាយ។

អង្គប្រជុំបានបញ្ចប់នៅម៉ោង៥ និង៤៥នាទីល្ងាច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**គណៈកម្មការមូលបត្រកម្ពុជា**

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Tempory Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh